ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៤៦៩ ប្រក

# ប្រកាស

## ស្តីពី

## ការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញប្រកាសលេខ ១៦៥ ប្រក/គ.ជ.អ.ប ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- យោងតាមសំណើរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន០២រូប ក្នុងរចនាសម្ព័ន្ធនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ ចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប ដូចមានរាយនាមខាងក្រោម៖

១. លោក **ឧត វណ្ណះ** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ១២នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ជាប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប។

២. កញ្ញា **គង់ ម៉ុណ្ណា** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ១៣នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ជាប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ២.-**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន០២រូប ក្នុងរចនាសម្ព័ន្ធនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ ចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប ដូចមានរាយនាមខាងក្រោម ៖

១. លោក **មុត រ៉ាយ** ឋានន្តរសក្តិក្រមការ ថ្នាក់លេខ១៣នៃក្របខ័ណ្ឌមន្ត្រីក្រមការ ជាអនុប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប។

២. លោក **ស សុបញ្ញា** ឋានន្តរសក្តិក្រមការ ថ្នាក់លេខ១៣នៃក្របខ័ណ្ឌមន្ត្រីក្រមការ ជាអនុប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ប្រធានអង្គភាពពាក់ព័ន្ធចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ និងប្រការ២ខាងលើត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

**កន្លែងទទួល ÷**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងមុខងារសាធារណៈ*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *សាលារាជធានី ខេត្ត*
- *ដូចប្រការ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*